**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា

# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្លែងក្នុងឱកាសបើក សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០

**ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០**

**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្ទប់ប្រជុំ “ខ”**

**និងតាមវីដេអូខនហ្វឺរេន កម្មវិធី BlueJeans**

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកធ្វើជាអធិបតីក្នុងពិធីបើកសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០ ដ៏មានសារៈសំខាន់ បន្ទាប់ពីកិច្ចប្រជុំពេញអង្គ ដែលបានប្រព្រឹត្តទៅកាលពីម្សិលមិញ។ ក្នុងឱកាសដ៏ប្រពៃនេះ ជាថ្មីម្ដងទៀត ខ្ញុំសូមសម្ដែងនូវអំណរគុណចំពោះវត្តមានដ៏មានតម្លៃរបស់ ឯកឧត្ដម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលចូលរួមបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០២១ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជារបស់យើង។

ក្នុងរយៈពេលមួយឆ្នាំនេះ យើងបានបំពេញភារកិច្ចយ៉ាងសកម្មរួមគ្នា ដើម្បីឈានទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងដំណាក់កាលដែលស្ថានភាពជំនួយពីបរទេសធ្លាក់ចុះរួមជាមួយនឹងការគំរាមកំហែងពីជំងឺកូវីដ-១៩ ដែលនៅតែបន្ត ហើយមកទល់ពេលនេះស្ថានភាពនៃ

ការឆ្លងរាតត្បាតជំងឺកូវីដ-១៩ នៅតែបង្កផលប៉ះពាល់យ៉ាងខ្លាំងជាសកលនៅឡើយ។ នៅក្នុងរយៈពេលផ្ទេរដំណាក់កាលនេះ យើងទាំងអស់គ្នាចាប់ផ្តើមបំពេញតួនាទីក្នុងភាពជាម្ចាស់ ដោយប្តេជ្ញារួបរួមគ្នាបញ្ចប់នូវការឆ្លងរីករាលដាលមេរោគអេដស៍នៅកម្ពុជា ក្នុងឆ្នាំ២០២៥-២០៣០។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ជាមួយគ្នានេះផងដែរ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកសមាជិកាអង្គសន្និបាតជ្រាបថា នៅក្នុងអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅព្រឹកនេះតាមរបៀបវារៈ យើងនឹងមានបទបង្ហាញចំនួនប្រាំ ដើម្បីជូនអង្គសន្និបាត។ ក្នុងនោះរួមមានបទបង្ហាញស្តីពី៖ ១) ស្ថានភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តកំពង់ស្ពឺ ២) ការត្រៀមអនុវត្តគំនិតផ្តួចផ្តើមទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ នៅខេត្តបាត់ដំបង ៣) លទ្ធផលការងារអន្តរាគមន៍លើប្រជាជនគន្លឹះ ៤) ការលេបថ្នាំបង្ការជាមុននៅពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ និង៥) សមិទ្ធផលឆ្នាំ២០២០ និងទិសដៅឆ្នាំ២០២១។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានជំនឿថា រយៈពេលពេញមួយព្រឹកនេះ អង្គសន្និបាតរបស់យើងនឹងទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗ ដែលបានមកពីការអនុវត្តជាក់ស្តែង របស់សមាជិកសមាជិកានៃអង្គសន្និបាតដែលអាចយកទៅប្រើប្រាស់ក្នុងការកែលម្អដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់ខ្លួនឱ្យបានកាន់តែល្អប្រសើរថែមទៀត ហើយនៅក្នុងរបៀបវារៈចុងក្រោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងធ្វើការបូកសរុបនូវលទ្ធផលនៃអង្គសន្និបាតទាំងមូល រួមជាមួយនឹងការបង្ហាញពីវិធីសាស្ត្រវិទ្យាសាស្ត្រមួយចំនួនក្នុងការពន្លឿនការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យមានប្រសិទ្ធភាពឆ្ពោះទៅសម្រេចបាននូវគោលដៅសូន្យបី។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ ការពិភាក្សា និងការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងចំណោមសមាជិក សមាជិកានៃអង្គសន្និបាត ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅពេលនេះ។ ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ឱ្យមានសុខភាពល្អ កម្លាំងមាំមួនក្នុងការចូលរួមពិភាក្សាឱ្យបានផុសផុល ដើម្បីទទួលបាននូវលទ្ធផលទៅតាមកម្មវត្ថុ ដែលបានគ្រោងទុក និងសូមប្រកាសបើក “**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០**” ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***